# សាសនានិងសិល្បៈ

សាសនានិងសិល្បៈ ជានិច្ចកាល គឺនៅជាប់នឹងជីវិតរបស់ខ្មែរ និងមានតួនាទីសំខាន់ព្រមទាំងជាចលករធ្វើឱ្យអរិយធម៌ខ្មែរអភិវឌ្ឍឬឱនថយ។ នៅក្នុងអត្ថបទនេះ ខ្ញុំនឹងបកស្រាយអំពីគំនិតនិងស្ថានភាព ដែលសាសនាប្រើសិល្បៈជាមធ្យោបាយ ដើម្បីបង្ហាញអំពីជំនឿនិងទំនៀមទម្លាប់មូលដ្ឋាននៅក្នុងប្រទេសកម្ពុជា។ ខ្ញុំក៏នឹងពិនិត្យមើលតួនាទីរបស់តន្ត្រី របាំ និងអក្សរសិល្ប៍នៅក្នុងប្រពៃណីព្រះពុទ្ធសាសនា ជារូបភាពសិល្បៈនិងអត្ថន័យអប់រំ ក៏ដូចជាឥទ្ធិពលនៃសាសនានិងសិល្បៈទៅលើវប្បធម៌បច្ចុប្បន្ននៃប្រទេសកម្ពុជា។

ការរួមបញ្ចូលគ្នានូវជំនឿអរូបី ព្រហ្មញ្ញសាសនា ហិនឌូសាសនា និងព្រះពុទ្ធសាសនា បានបង្កប់នៅក្នុងជំនឿរបស់ខ្មែររាប់រយពាន់ឆ្នាំមកហើយ។ ប្រវត្តិសាស្ត្រខ្មែរបានបង្ហាញថា ពីដើមឡើយ ខ្មែរយើងអនុវត្តជំនឿអរូបី ហើយក្រោយមកទៀត ទើបសាសនាឯទៀតៗត្រូវបានឧទ្ទេសនាមនិងមានវត្តមាននៅកម្ពុជា។ ក្នុងន័យនេះ ខ្មែរយើងមិនបានចាប់យកសាសនាដែលទើបនឹងហូរចូលមកថ្មី ហើយបោះបង់ជំនឿនិងសាសនាចាស់នោះឡើយ ពោលគឺយើងរក្សា និងបដិបត្តិជំនឿនិងសាសនាដែលមានទាំងអស់រួមគ្នា។

ដោយឡែក យើងឃើញថា សាសនានិងសិល្បៈ មានទំនាក់ទំនងនិងពាក់ព័ន្ធនឹងគ្នា។ សាសនា មានឥទ្ធិពលខ្លាំងក្លាទៅលើសិល្បៈ ជាពិសេស ស្ថាបត្យកម្ម ចម្លាក់ អក្សរសិល្ប៍ និងរបាំ។ សិលាចារឹក បានបង្ហាញថា ព្រះមហាក្សត្រខ្មែរ បានឧទ្ទិសស្រីរបាំដល់អាទិទេព និងបុព្វបុរសរបស់ព្រះអង្គ។ ដូច្នេះហើយបានជាយើងឃើញនៅលើប្រាសាទបុរាណនាសម័យអង្គរ មានស្រីរាំ តន្ត្រីករ និងតន្ត្រីការិនីជាច្រើន។[៦] ឯកសាររបាំ បានបញ្ជាក់ថារបាំទាំងឡាយមិនមែនគ្រាន់តែជាទស្សនីយភាពសម្រាប់តែការកម្សាន្តតែប៉ុណ្ណោះទេ តែថែមទាំងជាការបូជាសំខាន់ចំពោះព្រលឹងនៃអាទិទេពនិងបុព្វបុរស ដើម្បីសេចក្តីសុខនិងសេចក្តី

---

៦ Thierry 1963: 361, Sam 1988: 231-232, Sam 1997: 13-14

ចម្រើន។ នាបច្ចុប្បន្ន ការអនុវត្តជំនឿបុរាណក៏នៅមាននិងថែរក្សា ដូចជាការថ្វាយភ្លេងពិណពាទ្យ ព្រមទាំងដង្វាយផ្សេងៗជាដើម។

តន្ត្រី កំដរជីវិតរបស់ខ្មែរគ្រប់រូប ចាប់តាំងពីនៅក្នុងអង្រឹង ពោលគឺម្ដាយបំពេកូនដោយបង្កប់នូវអត្ថន័យខ្លឹមសារនៃដំបូន្មានសីលធម៌បុរាណ។ ពិធីផ្សេងៗ ពីខួបកំណើត ពិធីកោរសក់ (កោរជុក) ចូលម្លប់ បំបួសនាគ អាពាហ៍ពិពាហ៍ និងជំងឺ រហូតដល់ពិធីបុណ្យសព ដែលប្រារព្វឡើង គឺមិនគ្រប់គ្រាន់ពេញលេញឡើយ ប្រសិនបើគ្មានតន្ត្រីអមផង។ ពិធីបុណ្យជាតិនិងសាសនា ដូចជាចូលឆ្នាំ ភ្ជុំបិណ្ឌ សំពះគ្រូ និងអារក្ស ក៏តម្រូវឱ្យមានតន្ត្រីកំដរ។ លើសពីនេះទៅទៀត តន្ត្រីមានតួនាទីសំខាន់ក្នុងការកំដរសិល្បៈទស្សនីយភាពមានល្ខោននិងរបាំជាដើម។

ក្នុងរបាំ អ្នករាំរៀបចំធ្វើពិធីសំពះគ្រូ (ខ្នាតតូច) ដើម្បីបួងសួងសូមពរជ័យដល់ការសិក្សារៀនសូត្រសិល្បៈរបាំ មុននឹងចាប់មេរៀនទី១របស់គេ។[២] ពិធីនេះសំខាន់ណាស់ដែលអ្នករាំគ្រប់គ្នាប្រារព្វធ្វើហើយធ្វើទៀតនៅក្នុងឆាកជីវិតរបស់គេ ជាអ្នករាំ ដោយគេមានជំនឿថា **សម្ដេចព្រះគ្រូ** ដែលស្ថិតនៅក្នុងរបាំ នឹងតាមថែរក្សាគេនិងជូនពរជ័យដល់ការសិក្សារបស់គេ។

របាំព្រះរាជទ្រព្យ ឬ របាំក្បាច់បុរាណខ្មែរ ស្ថិតនៅជាប់ក្នុងព្រះបរមរាជវាំងខ្មែរជាងមួយពាន់ឆ្នាំមកហើយ និងមានប្រភពដើមចេញពីពិធីសក្ការៈនិងការបូជាឧទ្ទិសចំពោះបុព្វបុរស ដូច្នេះគេចាត់ទុកថាជា «របាំសក្ការៈ»។

នៅលើជញ្ជាំងប្រាសាទបុរាណនានាក្នុងព្រះរាជាណាចក្រកម្ពុជា គេឃើញមានរូបចម្លាក់អប្សរាចំនួន ១,៧៨៧ ដែលបញ្ជាក់និងឆ្លុះបញ្ចាំងពីយុគសម័យដ៏រុងរឿងរបស់ខ្មែរដែលសិល្បៈទស្សនីយភាពមានភាពល្ងូតលាស់ដល់កំពូល។[៣] ស្រីរាំទេពអប្សរទាំងនេះ

---

[២] Chan Moly Sam 1987: 13

[៣] Cravath 2007: 13

AMS អរិយធម៌ខ្មែរ

មានតួនាទីជាស្ពានបន្តភ្ជាប់ពីអាទិទេពមកមនុស្ស ដែលគេចាត់ទុកថាជា «ស្រីរាំសក្ការៈ» មានតួនាទីរាំដើម្បីបំពេញព្រះទ័យអាទិទេពនិងព្រលឹងរបស់បុព្វបុរស។

សាសនា ជាមូលដ្ឋានគ្រឹះនៃសង្គមខ្មែរ។ ព្រះពុទ្ធសាសនា ជាពិសេសការអប់រំ មានឥទ្ធិពលមកលើគំនិតនិងចរិតលក្ខណៈរបស់ខ្មែរ។ ជីវិតខ្មែរដែលគ្មានព្រះពុទ្ធសាសនា ជាជីវិតដែលគ្មានប្រពៃណី វប្បធម៌ និងអត្តសញ្ញាណ។ អវត្តមានព្រះពុទ្ធសាសនា ប្រៀបដូចជាការបំបែកនូវធាតុស្នូលនៃសង្គមនិងការរួបរួមសាមគ្គីសហគមន៍ ក៏ដូចជាជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្មែរ។ ដោយឡែក ខ្មែរយើងគិតថា អវត្តមានព្រះពុទ្ធសាសនា ក៏ដូចជាការបាត់បង់ភាពជាខ្មែរដូច្នោះដែរ។

យើងមានពាក្យស្លោកមួយឃ្លាថា «សាសនានិងសិល្បៈជាកញ្ចក់ឆ្លុះសង្គម»។ ប្រសិនបើនេះជាការពិត ព្រះពុទ្ធសាសនានិងសិល្បៈប្រាកដជាកញ្ចក់ឆ្លុះសង្គមខ្មែរ និងជាមូលដ្ឋាននៃវប្បធម៌ខ្មែរ។ ឧទាហរណ៍ ប្រាសាទអង្គរវត្ត ជាមោទកភាពនៃនិមិត្តសញ្ញាជាតិខ្មែរ សម្រាប់ខ្មែរគ្រប់ទំនោរ និន្នាការ ជាតិពន្ធុ កុម្មុយនីស្ត សង្គមនិយម សាធារណរដ្ឋនិយម ក៏ដូចជារាជានិយម។ ប្រាសាទអង្គរវត្ត មាននៅលើទង់ជាតិនៃរបបទាំងអស់ខាងលើនេះ។ លើសពីនេះទៅទៀត ខ្មែរយើងគ្រប់គ្នាយល់ថា របាំព្រះរាជទ្រព្យខ្មែរ ជានិមិត្តរូបនៃមោទនភាពនិងអត្តសញ្ញាណជាតិខ្មែរ។

នៅក្នុងបរិបទលូតលាស់ជឿនលឿននៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងបញ្ញាសិប្បនិម្មិត ជំពូកថ្មីមួយនឹងត្រូវសរសេរអំពីសាសនានិងសិល្បៈ ព្រមទាំងការសូនវប្បធម៌ខ្មែរ។ វាក៏ជាការប្រឈមមួយរវាងវប្បធម៌ប្រពៃណីនិងអត្តសញ្ញាណវប្បធម៌ នៅក្នុងដំណើរឆ្ពោះទៅមុខទៀត។ នេះជាទំនួលខុសត្រូវរបស់យើងបច្ចុប្បន្ននិងអ្នកជំនាន់ក្រោយជាអ្នកបន្តវេនដែលត្រូវអភិរក្ស ថ្នែប្រឌិត បណ្តុះបណ្តាល លើកស្ទួយ ការពារ និងថែរក្សាបន្តសម្បត្តិវប្បធម៌ដូនតាខ្មែរឱ្យគង់វង្ស លូតលាស់ និងរុងរឿង។ ការរីកចម្រើននិងវិវត្តន៍ ចាប់ផ្តើមពីការមើលត្រឡប់ទៅក្រោយ សិក្សា និងយល់ដឹងច្បាស់អំពីប្រពៃណីខ្មែរ។ បុរាណមិនឃើត ឯសម័យ

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

ក៏មិនមែនបរទេសដែរ។ ទំនើបនិងទាន់សម័យ ក៏មិនមែនមានន័យថា យើងត្រូវតែបោះបង់ចោលប្រពៃណីឡើយ តែយើងត្រូវរកវិធីនិងមធ្យោបាយថ្មី ដើម្បីបកស្រាយនិងបង្ហាញអំពីប្រពៃណីចាស់ឱ្យមានភាពទំនើប រំភើប ទាក់ទាញ អស្ចារ្យ និងពាក់ព័ន្ធទៅនឹងជំនាន់ កាលៈទេសៈពេលវេលា និងទីកន្លែង៕





អត្ថបទដោយ៖ បណ្ឌិត សំ សំអាង



# ឯកសារពិគ្រោះ

Cravath, Paul. (2007). *Earth in Flower*. Holmes Beach, FL: DatAsia.
Sam, Chan Moly. (1987). *Khmer Court Dance: A Comprehensive Study of Movements, Gestures, and Postures as Applied Techniques*. Newington, CT: Khmer Studies Institute.
Sam, Sam-Ang. (1988). *The Pin Peat Ensemble: Its History, Music, and Context.* Ph.D. Dissertation, Wesleyan University.
Sam, Yang. (1997). *Society, Administration, Economy, Religion, and Culture during the Angkor Period.* Unpublished paper.
Thierry, Solange. (1963). *Les Danses Sacrées*. Paris: Sources Orientales.

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង